# ពុទ្ធសាសនាថេរវាទនៅប្រទេសខ្មែរ

**RG asked:** Between Khmer and Thai, which country was the first to take this practice ? and Why ? Please elaborate ..

ខ្ញុំបាទបានលើកសំណួរបន្ទាត់ទី ៣ មកបកស្រាយជូនលោក មុននឹងខ្ញុំបាទបកស្រាយអំពីសំណួររបស់លោកពីរសំណួរទៀត ព្រោះជាពត៌មានខាងប្រវត្តិសាស្រ្ត មានបងប្អូនខ្មែរខ្វះបានយល់ថា ពុទ្ធសាសនាថេរវាទ បានចូលមកដល់ប្រទេសខ្មែរតាមរយៈប្រទេសសៀម ។ ខ្ញុំបាទបានលើកយករឿងនេះទៅសាកសួរព្រះតេជគុណជាព្រះភិក្ខុសង្ឃខ្មែរ ធ្លាប់សិក្សានៅឯនានាប្រទេស ជាពិសេសប្រទេសស្រីលង្កា ដើម្បីសូមព្រះវរណាព្រះអង្គ ជួយស្រាយបំភ្លឺចែកទានដល់ខ្ញុំបាទផង ។ រឿងនេះបានត្រូវលើកទូលសួរតាមរយៈ **Paltalk Chat Room: Khmer Dhamma Talk Live @ www.paltalk.com** ដែលតែងបានជួបជុំគ្នាធ្វើកិច្ចសន្ទនាអំពីពុទ្ធសាសនាខ្មែរ ជារៀងរាល់ល្ងាច ជួនកាលគ្នាច្រើន ជួនកាលគ្នាតិច តាមការគួរ ។

អាស្រ័យដោយពត៌មាន ទទួលបានពីព្រះភិក្ខុសង្ឃខ្មែរយើង រួមនឹងចំណេះដឹងស្តួចស្តើងដែលខ្ញុំបាទបានសិក្សាស្រាវជ្រាវតាមផ្នែកប្រវត្តិសាស្រ្តឃើញថា ពុទ្ធសាសនាថេរវាទ ទំនងជាបានត្រូវនាំមកដល់ប្រទេសខ្មែរតាមប្រភពមួយចំនួន ដែលមិនមែនជាប្រភពសៀមឡើយ ។

តាមរយៈលោកបណ្ឌិត សុង ស៊ីវ អ្នកនិពន្ធសៀវភៅដ៏ច្រើនជាភាសាខ្មែរ ទាក់ទងនឹងសាសនា វប្បធម៌ អារ្យធម៌ ប្រពៃណី និងទំនៀមទំលាប់ខ្មែរ បានសន្និដ្ឋានថា ពុទ្ធសាសនាថេរវាទ បានត្រូវផ្សព្វផ្សាយមកដល់ដែនសុវណ្ណភូមិ និងមកដល់ប្រទេសខ្មែរ ក្នុងសម័យអាណាចក្រនគរភ្នំ (ហ្វូណន) ។ សេចក្តីសន្និដ្ឋាននេះ ស្របគ្នានឹងការសិក្សាស្រាវជ្រាវរបស់ព្រះភិក្ខុ ប៉ាង ខាត់ ដែលបានរកឃើញថាខ្មែរមានរបចនាសម្ព័ន្ធរដ្ឋ តាំងពីដើមកំណើតនគរភ្នំមកម្ល៉េះ មិនមែនខ្មែរស្រាតនទលគក ដូចអ្នកប្រាជ្ញបារាំងខ្លះបានសន្និដ្ឋាននោះទេ ។ លោកអ្នកប្រាជ្ញខ្មែរពីររូបនេះ ទោះបានលើកសរសើរអំពីគុណសម្បត្តិលោក ហ្សកា សឺដែស្ស ដែលលោកពូកែស្រាវជ្រាវអំពីប្រវត្តិសាស្រ្តខ្មែរក៏ដោយ ក៏លោកអ្នកប្រាជ្ញខ្មែរទាំងពីរបានជំទាស់យោបល់នឹងលោក សឺដែស្ស ដែលនិយាយថាខ្មែរជាពួងមុនអារ្យធម៌ឥណ្ឌាចូលមកដល់ ។

តាមយោបល់របស់លោក វ៉ាយ ប៊ុក និយាយថា ពុទ្ធសាសនាថេរវាទ ភាសាសំស្រ្កឹតបានមកដល់ប្រទេសខ្មែរនាសម័យអាណាចក្រនគរភ្នំ (ហ្វូណន) ។

តាមកាលប្រវត្តិ នៃពុទ្ធសាសនាមហាយាន និយាយថាពុទ្ធសាសនាមហាយានកើតរូបរាងនៅក្រោយសង្គាយនាលើកទី ៣ ដែលបានធ្វើឡើងនៅប៉ាត្តណា (២៥០ មុន គ.ស.) ។ លោកបណ្ឌិត សុង ស៊ីវ និយាយថា ដល់មកខាងដើមពុទ្ធសតវត្សរ៍ទី ១២ មានពុទ្ធសាសនាលទ្ធិមហាយាន (អាចរិយវាទ) ចូលមកដល់ប្រទេសខ្មែរទៀត ហើយក៏បានរីកចំរើនជាងពុទ្ធសាសនាថេរវាទ ។

តាមប្រភពពង្សាវតាចិន ដែលជាកម្រងឯកសារយើងពឹងពាក់ ដើម្បីបានដឹងសេចក្តីអំពីប្រទេសខ្មែរយើងកាលពីសម័យបរមបូរាណ មុនសីលាចារឹកកើតមានឡើងនោះ បាននិយាយអំពីអ្នកបួសពុទ្ធសាសនាពីហ្វូណន ជាច្រើនអង្គបំពេញបេសកកម្មនៅឯប្រទេសចិន ។ នៅក្នុងរឿងរ៉ាវដែលចិនបានកត់ត្រាទុកនោះ មាននិយាយអំពីកិច្ចការប្រែគម្ពីរដីកា និងសំណេររបស់អ្នកបួសហ្វូណន តែមិនបាននិយាយថាគម្ពីរដីកានោះឈ្មោះអ្វី ចេញមកពីប្រភពហ្វូណន ឬក៏យកមកពីប្រភពឥណ្ឌា មកកាន់ហ្វូណនរួចហើយទៅដល់ប្រទេសចិន នោះក៏ឥតមាននិយាយឡើយ ។

កាលប្រវត្តិនៃពុទ្ធសានាថេរវាទ បាននិយាយថា ៖ **304** (B.E.)-(240 C.E.) Ven. Mahinda establishes

the Mahavihara (Great Monastery) of Anuradhapura, Sri Lanka. The Vibhajjavadin community living there becomes known as the Theravadins. Mahinda compiles the first of the Tipitaka commentaries, in the Sinhala language. Mahinda's sister, Ven. Sanghamitta, arrives in Sri Lanka with a cutting from the original Bo tree, and establishes the bhikkhuni-sangha in Sri Lanka.

តាមរយៈកំណត់ហេតុរបស់ ជីវ តាក្វាន់ ដែលលោកបានមកដល់ប្រទេសខ្មែរយើងនៅ គ.ស. ១២៩៦ បានអធិប្បាយអំពី អ្នកបួសពុទ្ធសាសនាថា គោរសក់ និងស្លៀកសំពត់ពណ៌លឿង ទុកស្មាស្តាំឲ្យទំនេរ ដែលទំនងជាបែបថេរវាទ ។

លោកបណ្ឌិត សុង ស៊ីវ និយាយថា ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី ៧ (គ.ស. ១១៨១?) ព្រះរាជធានីនៅអង្គរធំ ព្រះអង្គបានសាងព្រះពុទ្ធរូបមាស ប្រាក់ សំរិត ថ្ម និងរូបព្រះយមព្រះកាល តម្កល់គ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រ ទាំងអស់ចំនួនពីរម៉ឺនបួនពាន់អង្គ ព្រមទាំងបានបញ្ជូនព្រះរាជបុត្រ ព្រះនាមតាមលិន្ទៈ ទៅសិក្សាវិជ្ជាពុទ្ធសាសនានៅឯកោះសីរីលង្កា ។ ព្រះរាជបុត្រនេះ បានបួសជាភិក្ខុនៅឯវត្តមហាវិហារ ។ លោកវិលមកប្រទេសខ្មែរវិញក្នុង ព.ស. ១៧៣៣ ។

ពង្សាវតាលាវនិយាយថា ពួកលាវទទួលឥទ្ធិពលពុទ្ធសាសនាពីប្រទេសខ្មែរ ។ លាវមិននិយាយថាគេទទួលឥទ្ធិពលពុទ្ធសាសនាថេរវាទពីសៀមទេ ។ [**History, Buddhism, and New Religious Movements in Cambodia.** Edited by John Marston and Elizabeth Guthrie. University of Hawaii Press. 2004.page 9]

ការសន្និដ្ឋានរបស់ខ្ញុំបាទគឺ ពុទ្ធសាសនាថេរវាទ ទំនងជាងបានមកដល់ប្រទេសកម្ពុជាមុនសម័យមហានគរ ទោះបីមិនមានឯកសារណាមួយ ឲ្យខ្ញុំបាទលើកជាមូលដ្ឋានក៏ដោយ ក៏ខ្ញុំបាទយល់ថា យោបល់លោកបណ្ឌិត សុង ស៊ីវ ហាក់ដូចជាស្របនឹងពង្សាវតាចិន ដែលទាក់ទងនឹងការប្រែគម្ពីរដីកាក្នុងរយៈកាលនោះ ដែលទំនងជាទាក់ទងនឹងខ្សែស្រឡាយ <ថេរវាទ> ជាន់ដំបូងនៃពុទ្ធសាសនា ។ ទោះបីជាដូច្នោះក៏ដោយ ដើម្បីឆ្លើយបកស្រាយចំពោះសំណួរលោក ដែលបានសួរថា រវាងខ្មែរ និងសៀម តើប្រទេសណាមួយ បានទទួលឥទ្ធិពលពុទ្ធសានាថេរវាទមុនគេ? នោះខ្ញុំបាទអាចឆ្លើយដោយជាក់លក្ខថា គឺប្រទេសខ្មែរទទួលពុទ្ធសាសនាថេរវាទមុនសៀម ។

សេចក្តីសន្និដ្ឋានថា ប្រទេសខ្មែរទទួលឥទ្ធិពលពុទ្ធសាសនាថេរវាទមុនសៀម គឺសំអាងលើប្រវត្តិសាស្ត្រដូចតទៅនេះ ។

- ក្នុងរជ្ជព្រះបាទជ័យវរ្ម័នទី ៧ (គ.ស. ១២៤៣-១២៩៥) ប្រទេសខ្មែរពិតជាបានស្គាល់ប្រទេសស្រីលង្កា និងប្រាកដជាទទួលពត៌មានអំពីពុទ្ធសាសនាថេរវាទ ទើបព្រះមហាក្សត្របញ្ជូនរាជបុត្រព្រះអង្គឲ្យទៅបួសរៀន នៅឯវត្តមហាវិហារនោះកើត ។ ពង្សាវតាភូមារក៏មាននិយាយរឿងរាជបុត្រអង្គនេះ ។

- ក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ប្រទេសសៀមមិនទាន់ទាំងមានឯកភាពជាតិផង មិនអាចមានឥទ្ធិពល ខាងវប្បធម៌ឯណាផ្សព្វផ្សាយចូលមកប្រទេខ្មែរឡើយ ។

- ពុទ្ធសាសនានៅក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី ៧ ត្រូវអ្នកសិក្សាស្រាវជ្រាវសន្និដ្ឋានថាជាពុទ្ធសាសនាបែបមហាយាន តែចំណែកខ្ញុំបាទគិតថាសេចក្តីសន្និដ្ឋាននេះមិនទាន់ជាក់លក្ខនៅឡើយទេ ហើយអាចមានការប្រែប្រួល ប្រសិនបើយើងសិក្សា និងវិភាគដោយយកចិត្តទុកដាក់ថែមទៀត ។